**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សំណុំរឿងព្រហ្មទណ្ឌ**
លេខ: ៣៨៨
ចុះថ្ងៃទី: ០៦-០២-២០១២
ជំនុំជំរះលេខ: ៨៩២
ចុះថ្ងៃទី: ២៨-០៥-២០១២

**សាលក្រមព្រហ្មទណ្ឌ**
លេខ: ៤៩ ·ណ·
ចុះថ្ងៃទី: ១០-០៧-២០១២

# តាមនាមប្រជារាស្ត្រខ្មែរ
# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៩ ខែ មិថុនា ឆ្នាំ ២០១២ ដោយមានសមាសភាពជំនុំជម្រះដូចតទៅ:

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

**ដើម្បីជំនុំជម្រះ**

លើសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៨ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ដែលមាន:

-ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៤៤ ឆ្នាំ សញ្ជាតិខ្មែរ ឥស្លាម មុខរបរប្រធានក្រុមហ៊ុន ទីកន្លែងកំណើតនៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម ទីលំនៅបច្ចុប្បន្ននៅភូមិថ្មី ឃុំពពេល ស្រុកពញាក្រែក ខេត្តកំពង់ចាម ប្រពន្ធឈ្មោះ [redacted] ·រ· មានកូនចំនួន៥នាក់ ឪពុកឈ្មោះ [redacted] ·រ· ម្តាយឈ្មោះ [redacted] ·ស· ទោសពីមុនធ្លាប់ជាប់ពន្ធនាគារមួយដង ។

-ឃុំខ្លួនថ្ងៃទី ០៤ ខែ កុម្ភៈ ឆ្នាំ ២០១២ តាមដីកាបង្គាប់ឲ្យឃុំខ្លួនលេខ ២១៣ ត.ព្រ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ។

-លោក [redacted] និងលោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទ

-ជាប់ចោទពីបទ: មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីខែ មិថុនា ឆ្នាំ ២០០៩ និងក្នុងឆ្នាំ ២០១១ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ៣៩១.៣៩២ នៃក្រមព្រហ្មទណ្ឌ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស ទីលំនៅបច្ចុប្បន្នផ្ទះលេខ៣៣E០ ផ្លូវលេខ ១៧៤ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ។

-លោក [redacted] ជាមេធាវីការពារឲ្យដើមបណ្តឹងរដ្ឋប្បវេណី

-សាក្សីឈ្មោះ [redacted] មានទីលំនៅសព្វថ្ងៃផ្ទះលេខ ០៦ពាផ្លូវលំ សង្កាត់ឫស្សីកែវ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

-សាក្សីឈ្មោះ [redacted] ទីលំនៅសព្វថ្ងៃផ្ទះលេខ ៩៥ ផ្លូវលេខ ០១ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

-បានឃើញពាក្យបណ្តឹងរបស់ដើមបណ្តឹងឈ្មោះ [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ [redacted] ះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។

ឃើញរបាយការណ៍សំយោគលេខ ០១៧ រ.ប.ក ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់នាយកដ្ឋាននគរបាលព្រហ្មទណ្ឌ ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ ៨៧៥ រ.យ.ឆ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ១៥១០ ដ.ជ.រ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ ។

-ដីកាបង្គាប់ឲ្យនាំខ្លួនជនជាប់ចោទមកសាលាដំបូងរាជធានីភ្នំពេញលេខ ៦៩៨២ គ.ព្រ ចុះថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១២ របស់លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ ។

## អង្គហេតុនៃរឿងមានដូចតទៅ:

ក្នុងអំឡុងខែមិថុនា ឆ្នាំ២០០៩ ឈ្មោះ [redacted] ភេទប្រុស អាយុ ៤៣ ឆ្នាំ បាននិយាយលួងលោមអោយឈ្មោះ [redacted] ប្រគល់ប្រាក់ចំនួន ៥៣០០០$ (ប្រាំម៉ឺនបីពាន់ដុល្លារអាមេរិក) នៅពេលនោះឈ្មោះ [redacted] មានការជឿទុកចិត្តក៏ព្រមប្រគល់ប្រាក់ចំនួន ៥៣០០០$ (ប្រាំម៉ឺនបីពាន់ដុល្លារអាមេរិក) ទៅអោយឈ្មោះ [redacted] ហើយឈ្មោះនេះបានសរសេរមូលប្បទានប័ត្រចំនួន ០២ សន្លឹក អោយទៅឈ្មោះ [redacted] ប៉ុន្តែពេលឈ្មោះ [redacted] យកមូលប្បទានប័ត្រទៅបើកប្រាក់នៅធនាគារហើយធនាគារបញ្ជាក់ថាគ្មានទឹកប្រាក់ទេ ។ បន្ទាប់មកនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ឈ្មោះ [redacted] ក៏បានមកនិយាយលួងលោមខ្ចីរថយន្តរបស់ឈ្មោះ [redacted] ម៉ាក Mercedes S500 ផលិតឆ្នាំ២០០០ ដោយអះអាងថាយកទៅដឹកអ្នកវិនិយោគដែលមករកស៊ីក្នុងប្រទេសកម្ពុជា ក្រោយពីបានរថយន្តហើយឈ្មោះ [redacted] បែរជាយករថយន្តទៅបញ្ចាំទៅវិញ ហើយបានប្រើល្បិចលួងលោមយកប្រាក់ពីឈ្មោះ [redacted] ជាបន្តបន្ទាប់ដែល



Scanned by CamScanner

មានទឹកប្រាក់សរុបចំនួន ១២៧.៥៦២,៥០$ (មួយសែនពីរម៉ឺនប្រាំពីរពាន់ប្រាំរយហុកសិបពីរដុល្លាអាមេរិក និងហាសិបសេន) ទៀត ។

## ឆាពេលសចណការ

-ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា: កាលពីឆ្នាំ ២០០៩ ខ្លួនពិតជាបានឲ្យសែកទៅដើមបណ្តឹងឈ្មោះ [redacted] ចំនួនពីរសន្លឹក ដោយសែកមួយសន្លឹកមានទឹកប្រាក់ ១៤០០$ (មួយពាន់បួនរយដុល្លាអាមេរិក) និងមួយសន្លឹកទៀតមានទឹកប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លាអាមេរិក) ជាសែករបស់ក្រុមហ៊ុនមានសមាជិកបីនាក់ចុះហត្ថលេខា ទើបបើកលុយបាន ។ ខ្លួនបានឲ្យសែកនោះទៅឈ្មោះ [redacted] នៅចន្លោះខែឧសភា ឆ្នាំ២០០៩ សម្រាប់ទូទាត់ប្រាក់កំចីក្រៅប្រទេស ខ្លួនបានប្រាប់គាត់ដែរថា សែកនោះមិនទាន់មានទឹកប្រាក់ទេ រង់ចាំថៅកែក្រឡប់ពីក្រៅប្រទេស ហើយសែកនោះមិនទាន់មាន ាក់ថ្ងៃ ខែ ឆ្នាំទេ ។ ប៉ុន្តែក្រោយមកខ្លួនបានទូរទាត់ប្រាក់សុទ្ធទៅឲ្យដើមបណ្តឹងរួចរាល់ហើយ ប៉ុន្តែមិនបានយកមូលប្បទានប័ត្រមកវិញ ខ្លួនបានទារយកសែកនោះមកវិញដែរ តែលោ [redacted] ប្រាប់ថាគាត់ច្រឡំដៃមិនដឹងទុកនៅទីណា ម្យ៉ាងដោយមានការរាប់អានជឿទុកចិត្តគ្នា ខ្លួនមិនបានតាមទារទៀត ខ្លួនគ្មានសាក្សីណាមកបញ្ជាក់ថា ខ្លួនបានសងលុយដើមបណ្តឹងនោះទេ កន្លងមកខ្លួន និងដើមបណ្តឹងធ្លាប់មានការរាប់អានគ្នា ហើយនៅពេលខ្លួនខ្វះខាតលុយកាក់បន្តិចបន្តួច គាត់ពិតជាបានជួយខ្លួន ។

ចំពោះបញ្ហាដែលដើមបណ្តឹងចោទប្រកាន់ថា ខ្លួនរំលោភលើទំនុកចិត្តនោះ ជាការមិនពិតទេ ដោយហេតុថារថយន្តម៉ាក Mercedes S500 ផលិតឆ្នាំ២០០០ ពីដំបូងឡើយជាឡានរួមគ្នារវាងរូបខ្លួន និងដើមបណ្តឹងដោយលុយបានមកពីកំរៃជើងសារលក់ផ្លូវសឡាឲ្យក្រុមហ៊ុនស៊ិនទ្រីបានចំនួន ២០០០០$ (ពីរម៉ឺនដុល្លារអាមេរិក) ហើយនៅពេលខ្លួនខ្វះខាតលុយក៏ប្រាប់ដើមបណ្តឹងថា សុំយកឡានទៅដាក់បញ្ចាំសិន ហើយដើមបណ្តឹងក៏បានឯកភាពដែរ ទើបខ្លួនយកទៅបញ្ចាំបាន ។ ដំបូងឡើយឡានមានតែសំបុត្រពន្ធទេ ប៉ុន្តែសព្វថ្ងៃនេះដើមបណ្តឹងបានយកកាត់ដាក់ឈ្មោះគាត់ហើយ ។ ខ្លួនបានយកឡានទៅបញ្ចាំយកលុយ ១៥០០០$ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) យកលុយលេងល្បែងនៅ ណាហ្គា តែក្រោយមកខ្លួនបានយកលុយផ្ទាល់ខ្លួន ចំនួន ១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) និងលុយរបស់ដើមបណ្តឹងខ្លះយកទៅលោះរថយន្តមកវិញ ។ ខ្លួនរត់ដែលមានទទួលលុយផ្សេងពីដើមបណ្តឹងទេ ចំពោះការទាមទាររបស់ដើមបណ្តឹងថា ខ្លួនបានជំពាក់ប្រាក់គាត់ជាងដប់ពីរម៉ឺនដុល្លារអាមេរិកនោះ ខ្លួនមិនទទួលស្គាល់ទេ ខ្លួនទទួលស្គាល់ថាបានចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ ។ ចំពោះលិខិតធានាសងប្រាក់ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១ គឺឈ្មោះ [redacted] បានមកជួបខ្លួននៅផ្ទះ គាត់មកជាមួយ

3



Scanned by CamScanner

ឈ្មោះ [redacted] និយាយលួងលោមខ្លួនថា គាត់មានរឿងជាមួយប្រពន្ធរបស់គាត់ ដើម្បីឲ្យប្រពន្ធគាត់មានការទុកចិត្តទើបឲ្យខ្លួនធ្វើលិខិតធានាសងប្រាក់ទៅដើមបណ្តឹង ។

ចំពោះលិខិតធានាសងប្រាក់ចុះថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១១ នោះខ្លួនទទួលស្គាល់តែទឹកលុយចំនួន ២០០០០$ (ពីរម៉ឺនដុល្លារអាមេរិក) រីឯទឹកលុយចំនួន ៨០០០០$ (ប្រាំបីម៉ឺនដុល្លាអាមេរិក) ខ្លួនមិនទទួលស្គាល់ទេ គឺជាលុយកុំម៉្យុងការងាររត់ ស.ជ.ណ សាងសង់ផ្សារចាស់,ផ្សារកណ្តាល,ផ្សារថ្មី ខ្លួនបានប្រាប់ដើមបណ្តឹងកុំឲ្យគាត់ប្តឹងគេអី ចាំខ្លួនចេញឲ្យ ។ ខ្លួនទទួលស្គាល់តែបទល្មើសចេញសែករអត់លុយ តែមិនទទួលស្គាល់បទល្មើស រំលោភលើទំនុកចិត្ត ទេ ។ ដើមបណ្តឹងមានចេតនាប្តឹងបង្កាច់បង្ខូចកិត្តិយសខ្លួនដើម្បីដណ្តើមអតិថិជនរបស់ខ្លួន ដោយគាត់ឃើញថាខ្លួនស្គាល់អ្នករកស៊ីធំៗក្រៅប្រទេសច្រើន ។

-ដើមបណ្តឹងឈ្មោះ [redacted] បានឆ្លើយថា: ដើមឡើយពាក់ពន្ធ័សាច់ប្រាក់រវាងម្ចាស់លុយម្នាក់ គេឲ្យខ្លួនជួយចរចារជាមួយអ្នកជំពាក់លុយគេ ហើយខ្លួនយល់ដល់ជនជាប់ចោទថាជាអ្នកគោរពសន្យាទើបខ្លួនស្រឡាញ់រាប់អានគាត់។ ដល់ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១១ គាត់ត្រូវគេចាប់ឃុំខ្លួននៅព្រៃសខ្លួនទូរស័ព្ទទៅគាត់ តែគាត់ប្រាប់ថាចាំគាត់ចេញពីគុកវិញចាំនិយាយគ្នា ខ្លួនធ្លាប់ជួយចេញចំណាយក្នុងពេលគាត់ជាប់គុក ថ្លៃចំណាយផ្សេងៗក្នុងក្រុមគ្រួសារគាត់ ដោយគាត់មានប្រពន្ធ២ ធ្លាប់ជួយចេញចំណាយផ្សេងៗជូលមេធាវីឲ្យគាត់ រហូតគាត់ចេញពីគុក គាត់ជាប់គុកពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១១ ចេញពីគុកនៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ ។ ជនជាប់ចោទពិតជាបានចេញសែកគ្មានលុយឲ្យខ្លួនមែន ចំពោះភាគីអ្នកលក់ផ្លូវសឡាគេអ្នកឲ្យកុំម៉្យុង ខ្លួនអត់ដឹង ។ ឡានខ្លួនទិញពីលោក [redacted] ក្នុងតម្លៃ ២០០០០$ (ពីរម៉ឺនដុល្លារអាមេរិក) បើបង់រំលស់ បើបង់ភ្លាម តម្លៃ ១៨០០០$ (មួយម៉ឺនប្រាំបីពាន់ដុល្លារអាមេរិក) ចំពោះការលើករបស់ជនជាប់ចោទថាខ្លួនឯកភាពឲ្យគាត់យកឡានទៅដាក់បញ្ចាំយកលុយទៅលេងល្បែងណាហ្គា ខ្លួនមិនបានដឹងទេ ដោយខ្លួនជាអ្នករកស៊ីមិនមានចំណូលចិត្តខាងលេងល្បែង គ្មានពេលវេលាទេ។ ឡានមានតែកុងសេរ៉ាប់ជូនជនជាប់ចោទទៅណាម្តងម្កាល ខ្លួនដឹងថាជនជាប់ចោទយកឡានទៅដាក់បញ្ចាំនៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១១ ជនជាប់ចោទបាននិយាយថា បើមានលុយ ៥០០០$ (ប្រាំពាន់ដុល្លារអាមេ រិក) ទៅលស់នៅកុងស៊ី គេឲ្យឡានមកវិញនៅថ្ងៃទី ២៤ លុះដល់ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ខ្លួនសួរទៀតគេថាត្រូវមានលុយ ១៥០០០$ (មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ទៅលស់ តែតាមការពិតគាត់យកលុយទៅលេងល្បែងនៅណាហ្គាដដែល ។ ហើយខ្លួនក៏សម្រេចចិត្តយកលុយចំនួន ១៦៥០០$ (មួយម៉ឺនប្រាំមួយពាន់ប្រាំរយដុល្លារអាមេរិក) ទៅលស់យកឡានមកវិញ។ នៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១១ គាត់យកលុយពីខ្លួនថាទៅលស់យកប៉ាស្ព័រ ដើម្បីទៅម៉ាឡាស៊ីយក

លុយមកសងខ្លួន ក្រោយមកខ្ចី ៦០០០$ (ប្រាំមួយពាន់ដុល្លារអាមេរិក) ថាសម្រាប់ទិញសំបុត្រយន្តហោះហើយ នៅថ្ងៃទី ២៥ ខ្លួនចេញសែកឲ្យជនជាប់ចោទចំនួន ១៥០០$ (មួយពាន់ប្រាំរយដុល្លារអាមេរិក) ទៀត ខ្លួនចាក់ ATM ឲ្យសរុបអស់ចំនួន ៦៥០០$(ប្រាំមួយពាន់ដុល្លារអាមេរិក) ហើយខ្លួនបានចេញសែកចំនួន ១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) ឲ្យទៅតាមឈ្មោះ [redacted] សម្រាប់យកទៅលស់ឡានតែជនជាប់ចោទយកទៅលេងល្បែងអស់ភ្លាមៗ ៣០០០$ (បីពាន់ដុល្លារអាមេរិក) សរុបទៅក្នុងការលស់យករថយន្តមកវិញ ខ្លួនត្រូវចំណាយប្រាក់អស់ប្រហែល ៤០០០០$ (បួនម៉ឺនដុល្លារអាមេរិក)។ ខ្លួនចំណាយលុយអស់យ៉ាងច្រើនដើម្បីលស់យកឡានមកវិញឲ្យប្រពន្ធខ្លួន កុំឲ្យមានរឿងក្នុងគ្រួសារ។ សែកពីរសន្លឹក ដោយមួយសន្លឹកមានទឹកប្រាក់ចំនួន ១៤០០$(មួយពាន់បួនរយដុល្លារអាមេរិក) និងមួយសន្លឹកទៀតចំនួន ៣០០០$(បីពាន់ដុល្លារអាមេរិក) ជនជាប់ចោទបាននិយាយថាបើពេលណាគេគ្មានប្រាក់សងខ្លួនទេ ឲ្យខ្លួនប្ដឹងចុះ ខ្លួនបានយកសែកទៅបើកលុយនៅធនាគារកម្ពុជាសាធារណៈ តែគ្មានប្រាក់ក្នុងគណនីទេ ជនជាប់ចោទមានសែកពាន់ សម្រាប់ដើរបោកគេ គឺគេគ្មានទឹកប្រាក់ក្នុងគណនីទេ សំណូមពរសុំឲ្យតុលាការដាក់ទណ្ឌកម្មជនជាប់ចោទឲ្យបានធ្ងន់ធ្ងរ បើតុលាការពិនិត្យឃើញថា ជនជាប់ចោទប្រព្រឹត្តមិនរាងចាល និងសុំឲ្យសងលុយខ្ញុំបាទចំនួន ១២៧៥៦២,៥០$ (ដប់ពីរម៉ឺនប្រាំពីរពាន់ប្រាំរយហុកសិបពីរដុល្លារអាមេរិក និងហាសិបសេន) ។

-សាក្សីឈ្មោះ [redacted] បានឆ្លើយថា: ខ្លួនជាអ្នកបើកបរឡានឲ្យដើមបណ្ដឹង ក្នុងរឿងនេះខ្លួនដឹងថាជនជាប់ចោទយកឡានរបស់ដើមបណ្ដឹងទៅបញ្ចាំ ។ ដំបូងលោក [redacted] បានប្រាប់ខ្លួនឲ្យដឹកជនជាប់ចោទទៅជួបភ្ញៀវនៅសណ្ឋាគារកាំបូឌីយ៉ាណា គឺនៅថ្ងៃទី ២៨ ខែមករា ឆ្នាំ ២០១១ ម៉ោងប្រហែល ៩ព្រឹកជាង ពេលទៅដល់លោក [redacted] ឡើងទៅលើ ខ្លួនអង្គុយចាំខាងក្រោម ពេលជនជាប់ចោទចុះមកវិញ គាត់ឲ្យខ្លួនដឹកជូនគាត់ទៅណាហ្គាវើល ឲ្យខ្លួនអង្គុយចាំគាត់ទៅជួបភ្ញៀវ ខ្លួនចាំប្រហែល១ម៉ោង ទើបគាត់ត្រឡប់មកវិញឲ្យខ្លួនយកសោរឡានឲ្យគាត់សុំមើលឡាន គាត់និយាយថាគាត់ចង់ទិញឡានពីដើមបណ្ដឹងក្នុងតំលៃ ២៥០០០$ (ពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក) ខ្លួនសុំទៅដែរ តែគាត់ឲ្យខ្លួននៅអង្គុយចាំ ជនជាប់ចោទប្រាប់ថាឲ្យខ្លួនហូបអីហូបទៅ ខ្លួនចាំរហូតដល់ម៉ោង៧យប់ ជនជាប់ចោទប្រាប់ថាឲ្យខ្លួនទៅផ្ទះទៅអត់អីទេ ឡានត្រូវថ្លៃគ្នាហើយ ចាំឲ្យគេជូនគាត់ទៅផ្ទះ ។ លុះក្រោយមកថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១ ដើមបណ្ដឹងចេញសែកឲ្យខ្លួនមានទឹកប្រាក់ចំនួន ១០០០០$(មួយម៉ឺនដុល្លារអាមេរិក) ឲ្យទៅបើកលុយនៅធនាគារបានលុយយកទៅប្រគល់ឲ្យជនជាប់ចោទ ដើម្បីយកទៅលស់ឡានបានមួយក្ដែតខ្លួនដឹងថាជនជាប់ចោទយកលុយទៅលេងល្បែងអស់ ៣០០០$ (បីពាន់ដុល្លារអាមេរិក) ដើមបណ្ដឹងបានឲ្យខ្លួនទៅយកលុយពីគាត់ចំនួន ៥០០០$(ប្រាំពាន់ដុល្លារអាមេរិក) ពី



Scanned by CamScanner

ផ្ទះឈ្មោះ[redacted]ចំនួន ២០០០$(ពីរពាន់ដុល្លារអាមេរិក) ទៅយកដល់ផ្ទះ រហូតដល់ពេលល្ងាចម៉ោង៧យប់ ទើបលស់យកឡានបានវិញ ។ ខ្លួនដឹងថារថយន្តនេះជារបស់លោក[redacted]ខ្លួនអត់ដឹងពីឯកសាររថយន្តទេ ។

-ក្រឡាបញ្ជីអានលិខិតបញ្ជាក់របស់ធនាគារកម្ពុជាសាធារណៈចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០១១ មានដូចជា:

-១០០ សំវិធានវត្ថុគ្មាន ឬមិនគ្រប់គ្រាន់

-១១០ សំវិធានវត្ថុមិនទាន់បានជំរះ

-១២០ បញ្ឈប់ការទូទាត់

-២២០ កាលបរិច្ឆេទមិនត្រឹមត្រូវ

-២៣០ ហួសកាលបរិច្ឆេទ (លើសពី៦ខែ)

-៣១០ ខ្វះចំនួនទឹកប្រាក់ជាអក្សរ

-៣៥០ ទិន្នន័យនៅលើមូលប្បទានប័ត្រ និងទិន្នន័យអេឡិចត្រូនិចមិនស្មើគ្នា

-៤០០ ហត្ថលេខារបស់បញ្ញើករខុសពីគំរូហត្ថលេខា

-៤១០ ខ្វះហត្ថលេខារបស់បញ្ញើករ

-៤២០ ខ្វះហត្ថលេខារបស់បញ្ញើករចំពោះការផ្លាស់ប្តូរ

-៤៣០ ខ្វះត្រារបស់បញ្ញើករ (ក្នុងករណីដែលមានចែងក្នុងគំរូហត្ថលេខា)

-៥០០ មិនចេញផ្សាយតាមគំរូធនាគារ

-៥១០ មូលប្បទានប័ត្រខូចខ្ទី

-៥២០ ធនាគារឈប់សំរាកជាផ្លូវការ

-៦០០ គណនីត្រូវបានបិទ

-៦១០ គ្មានគណនី

-៦២០ គណនីឃាត់ទុក

-៦៣០ បញ្ញើករធនក្ស័យ ត្រូវជំរះបញ្ជី

-៧០០ មូលហេតុផ្សេងៗ

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុតាងលេខ ៩៤ អ.ឃ.ឆ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញមានដូចជា:

១/-ទូរស័ព្ទដៃចំនួន ០២គ្រឿង ម៉ាក Samsung និងម៉ាក Nokia ។

២/-សៀវភៅគ្រួសារលេខ ១៧៧ ចំនួន ០១ក្បាល ។

៣/-លិខិតឆ្លងដែនលេខ ០៥៣៧០១៣ ចំនួន ០១ក្បាល ។



Scanned by CamScanner

៤/-សៀវភៅធនាគារ Cambodia Pubic Bank លេខ ០៩១២៨១ ចំនួន ០១ក្បាល ។

៥/-សែកធនាគារកម្ពុជាសាធារណៈ ចំនួន ០៣ក្បាល ។

៦/-លិខិតទិញលក់រថយន្ត ០៣សន្លឹក ។

៧/-រថយន្តមួយគ្រឿងម៉ាក RAV 4 ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ ២A ៨៥៥៨ ។

៨/-សែកធនាគារកាណាឌីយ៉ាចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ដែលមានទឹកប្រាក់ចំនួន ២៣០ ០០០ USD (ម្ភៃបីម៉ឺនដុល្លារអាមេរិក) ចំនួន ០១សន្លឹក ។

៩/-សែកធនាគារ May Bank ចំនួន ០៤សន្លឹក មួយសន្លឹកមានទឹកប្រាក់ចំនួន ១៧០ ០០០ (ដប់ប្រាំពីរម៉ឺនដុល្លារអាមេរិក) ។

១០/-សែកធនាគារកម្ពុជាសាធារណៈ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលមានទឹកប្រាក់ចំនួន ៨០ ០០០ USD (ប្រាំបីម៉ឺនដុល្លារអាមេរិក) ចំនួន ០១សន្លឹក ។

-លោក [redacted]ជាមេធាវីការពារឲ្យដើមបណ្តឹងបានធ្វើសេចក្តីសន្និដ្ឋានថា: អង្គហេតុនេះត្រូវបានជនជាប់ចោទទទួលស្គាល់សែកចំនួនពីរសន្លឹកជារបស់ខ្លួន ហើយកូនក្តីខ្លួនបានទៅបើកសែកនោះនៅធនាគារ គេថាគ្មានសាច់ប្រាក់។ ជនជាប់ចោទបានបដិសេធថាមិនបានឆបោក គឺដើមបណ្តឹងបានឯកភាពឲ្យខ្លួនយកឡានទៅបញ្ចាំ តែដើមបណ្តឹងបានបញ្ជាក់ថា ខ្លួនមិនបានព្រមព្រៀងឲ្យជនជាប់ចោទយកឡានទៅបញ្ចាំទេ។ ជនជាប់ចោទធ្លាប់បានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារមួយឆ្នាំ អនុវត្តទោសបានបួនខែ ទោសនៅសល់ត្រូវព្យួរតែជនជាប់ចោទមិនរាងចាលក្រោយចេញពីពន្ធនាគារនៅតែចេញសែកគ្មានលុយបំពានច្បាប់ ។ បើជនជាប់ចោទដឹងថាសែកហួសការបរិច្ឆេទហើយហេតុដូចម្តេចក៏ជនជាប់ចោទនៅតែចេញសែកឲ្យកូនក្តីខ្លួនទៀត ។ ជនជាប់ចោទបានទទួលស្គាល់ថាគេបានយករថយន្តទៅបញ្ចាំ កូនក្តីខ្លួនបានបញ្ជាក់ហើយថាគាត់បានជឿជនជាប់ចោទដែលល្បួងលោម ទើបជឿការអះអាងរបស់ជនជាប់ចោទ ហើយសុខចិត្តឲ្យលុយខ្ចីដើម្បីមានប្រយោជន៍ទៅថ្ងៃក្រោយ ដោយជនជាប់ចោទស្គាល់គេច្រើននៅក្រៅប្រទេស ។ សុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទឲ្យបានតឹងរឹងយោងភាពមិនរាងចាលរបស់ជនជាប់ចោទ និងសុំទាមទារប្រាក់ដើម និងជំងឺចិត្ត ដូចក្នុងពាក្យបណ្តឹង ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: ផ្អែកតាមដីកាសន្និដ្ឋានស្ថាពរលេខ ៨៧៥ អ.យ.ង ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២ របស់តំណាងអយ្យការ និងដីកាបញ្ជូនរឿងឲ្យជំនុំជម្រះលេខ ១៥១០ ដ.ជ.រ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ របស់ចៅក្រមស៊ើបសួរបានចោទប្រកាន់លើឈ្មោះ [redacted]ភេទប្រុស អាយុ ៤៣ឆ្នាំ ពិរុទ្ធ មិន



Scanned by CamScanner

បំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ។ ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការ និងចម្លើយដើមបណ្តឹង ព្រមទាំងចម្លើយរបស់សាក្សីរួចមកឃើញថា: មានពិរុទ្ធភាពគ្រប់គ្រាន់ដែលអាចបញ្ជាក់ថាជនជាប់ចោទឈ្មោះ [redacted] ជាបានប្រព្រឹត្តអំពើដូចការចោទប្រកាន់មែន ។ តំណាងអយ្យការសុំតាមការចោទប្រកាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ ឆ្នាំ ពីបទ: មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ទុកជាបានការដដែល សុំឲ្យតុលាការផ្តន្ទាទោសជនជាប់ចោទ តាមច្បាប់ ។

-លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទនាពេលសវនាការមានអង្គហេតុពីរគឺ: ទីមួយ ចេញមូលប្បទានប័ត្រគ្មានទឹកប្រាក់ ហើយតាមលិខិតបញ្ជាក់របស់ ធនាគារកម្ពុជាសាធារណៈ ឃើញថាសន្លឹកមូលប្បទានប័ត្រមានភាពមិនត្រឹមត្រូវដោយខុសការបរិច្ឆេទលើសង់ខែផុតរយៈពេលប្តឹង . រាល់សែកត្រូវមានហត្ថលេខារបស់សមាជិកភាគហ៊ុន តែនៅលើសែកខ្វះហត្ថលេខាបហារ៉ក . គណនីរបស់កូនក្តីខ្លួនត្រូវបានបិទយូរហើយ តែដើមបណ្តឹងនៅតែយកសែកទៅបើកទៀត ។ ដើមបណ្តឹងបានឆ្លើយនាពេលសវនាការថា មិនបានសរសេរបំពេញលើសែក ប៉ុន្តែនៅពេលសួរតទល់នៅចៅក្រមស៊ើបសួរ ដើមបណ្តឹងទទួលស្គាល់ថាជនជាប់ចោទចេញសែកឲ្យតាំងពីបីឆ្នាំមុន ចម្លើយនេះមានភាពស៊ីសង្វាក់នឹងចម្លើយកូនក្តីខ្លួន នឹងមានភាពស៊ីសង្វាក់ក្នុងការវាយតំលៃរបស់ធនាគារ នាំឲ្យកូនក្តីខ្លួនគ្មានធាតុផ្សំគ្រប់គ្រាន់ពីបទចេញមូលប្បទានប័ត្រខុសច្បាប់នោះទេ ។ ទីពីរ ចំណុចដើមបណ្តឹងថា កូនក្តីខ្លួនរំលោភលើទំនុកចិត្ត តែគ្មានឯកសារបញ្ជាក់ពីការទិញលក់រថយន្តឡើយ ដើមបណ្តឹងថា ទិញឡានពីឈ្មោះ [redacted] តែលោក [redacted] មិនដែលចូលឆ្លើយទេ សាក្សីសំខាន់គឺលោក [redacted] ប្រែរជាគ្មានវត្តមានលោកចូលមកបំភ្លឺតុលាការទេចំពោះចម្លើយសាក្សីឈ្មោះ [redacted] ថាយកលុយម្តង ១០០០០$ (មួយម៉ឺនដុល្លារអាមេរិក) ៥០០០$(ប្រាំពាន់ដុល្លារអាមេរិក) ២០០០$(ពីរពាន់ដុល្លារអាមេរិក) ទៅឲ្យកូនក្តីខ្លួនលស់ឡាន គឺគ្មានភស្តុតាងបញ្ជាក់ ហើយដើមបណ្តឹងថាយករហូត ៤០០០០$(បួនម៉ឺនដុល្លារអាមេរិក) ទៅលស់ឡានមកវិញ តែគ្មានសាក្សី ឬឯកសារណាបញ្ជាក់ មិនដឹងថាកូនក្តីខ្លួនបានទទួលលុយអីរត់ រឿងចោទពីបទ រំលោភលើទំនុកចិត្ត គ្រាន់តែជាវិមតិសង្ស័យ . ដាក់ស្លែងឡាននៅលើដៃរបស់ដើមបណ្តឹង ធាតុផ្សំបទរំលោភលើចិត្ត លុះត្រាវត្ថុដើមកម្មវត្ថុនៃបទល្មើសនៅលើដៃអ្នកទី៣ តែដាក់ស្លែងឡាននៅលើដៃរបស់ដើមបណ្តឹង សាក្សីសំខាន់គឺឈ្មោះ [redacted] តែគាត់មិនចូលមកបំភ្លឺ ។ សុំឲ្យតុលាការលើកលែងចោទពី



Scanned by CamScanner

បទ ចេញមូលប្បទានប័ត្រគ្មានប្រាក់ , សុំចាត់របៀបលើចំណុចទី២ ដើម្បីហៅសាក្សីឈ្មោះ [redacted] មកបំភ្លឺ ។

-លោក [redacted] ជាមេធាវីការពារឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: សុំឯកភាពសេចក្តីសន្និដ្ឋានរបស់មេធាវី [redacted] ដោយចំណុចទី១ ពុំមានធាតុផ្សំគ្រប់គ្រាន់កូនក្តីខ្លួនចេញមូលប្បទានប័ត្រមែន មានហត្ថលេខាតែម្នាក់ឯង ខ្វះពីរនាក់ទៀត ក្រោយមកកូនក្តីខ្លួនបានចេញលុយសុទ្ធឲ្យដើមបណ្តឹងរួចហើយ ។ សុំឲ្យតុលាការលើកចោលចំណុចទី១ , សុំចាត់របៀបចំណុចទី២ ដើម្បីហៅសាក្សីឈ្មោះ [redacted] មកបំភ្លឺ ។

-ជនជាប់ចោទឈ្មោះ [redacted] បាននិយាយសំដីចុងក្រោយថា: សុំឲ្យតុលាការលើកលែងចោទប្រកាន់ ដើម្បីមានពេលវេលារកស៊ីចិញ្ចឹមកូនប្រាំនាក់ , ឪពុកចាស់អាយុ ៩០ , ដែលគាត់ធ្លាប់ជួយកូនខ្មែរជាច្រើននាក់, ដើមបណ្តឹងមានបំណងបរិហារកេរ្តិ៍ខ្លួនដើម្បីឲ្យខ្លួនបាត់បង់ការងារប៉ុណ្ណោះ ដោយឃើញខ្លួនស្គាល់អ្នកមានបរទេសជាច្រើននាក់ ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់ចម្លើយដើមបណ្តឹង

-ក្រោយពីបានស្តាប់ចម្លើយរបស់សាក្សី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារដើមបណ្តឹង

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារ ភស្តុតាង ត្រឹមត្រូវហើយ

-ក្រោយពីបានពិនិត្យ ពិចារណា និងពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ៣៨៤ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ មកជំនុំជម្រះពីចៅក្រមស៊ើបសួរ តាមដីកាបញ្ជូនរឿងឲ្យជំនុំជម្រះលេខ ១៥១០ ដ.ជ.រ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០១២ដោយចោទប្រកាន់ជនជាប់ចោទឈ្មោះ [redacted] ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត តាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយបដិសេធថា: ខ្លួនមិនបានទទួលប្រាក់ចំនួន ១២៧៥៦២,៥០$ (មួយសែនពីរម៉ឺនប្រាំពីរពាន់ប្រាំរយ...



Scanned by CamScanner

ហុកសិបពីរដុល្លារអាមេរិក និងហាសិបសេន) ពីឈ្មោះ [redacted] និងបានអះអាងថា ខ្លួនបានយករថយន្តរបស់ដើមបណ្តឹងទៅបញ្ចាំដោយមានការព្រមព្រៀងរបស់ដើមបណ្តឹង នេះគ្រាន់តែជាចម្លើយដោះសារដើម្បីឲ្យរួចពីបទចោទប្រកាន់តែប៉ុណ្ណោះ ផ្អែកតាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] និងចម្លើយរបស់សាក្សីឈ្មោះ [redacted] និងភស្តុតាងនៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នាគួរឲ្យតុលាការជឿបានថា កាលពីខែមិថុនា ឆ្នាំ ២០០៩ និងឆ្នាំ ២០១១ ជនជាប់ចោទពិតជាបានចេញមូលប្បទានប័ត្រពីរសន្លឹក ដែលគ្មានទឹកប្រាក់ឲ្យទៅដើមបណ្តឹងនិងរំលោភលើទំនុកចិត្តរបស់ដើមបណ្តឹងឈ្មោះ [redacted] ប្រាកដមែន ។

៣-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយនាពេលសវនាការថា: ខ្លួនពិតជាបានចេញសែកចំនួនពីរសន្លឹកឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពិតប្រាកដមែន <u>សែកទី១</u> មានទឹកប្រាក់ចំនួន ១៤០០$ (មួយពាន់បួនរយដុល្លារអាមេរិក) <u>សែកទី២</u> លេខ ៧១៩២១២ មានទឹកប្រាក់ចំនួន ៣០០០$ (បីពាន់ដុល្លារអាមេរិក) នៅធនាគារកម្ពុជាសាធារណៈ ចំការគ៌ភ្នំពេញ ហើយប្រាក់នេះជនជាប់ចោទអះអាងថា ខ្លួនបានទូទាត់សងរួចហើយ តែចម្លើយនេះគ្មានភស្តុតាងណាមួយមកបញ្ជាក់ឲ្យតុលាការជឿបានឡើយ សែកខាងលើត្រូវបានដើមបណ្តឹងរដ្ឋប្បវេណីយកទៅបើក តែខាងធនាគារកម្ពុជាសាធារណៈចំការគ៌បញ្ជាក់តាមលិខិតចុះថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០១១ ថា គ្មានទឹកប្រាក់នៅក្នុងគណនីទេ ។ ជាទូទៅ ការចេញសែកត្រូវតែមានទឹកប្រាក់សម្រាប់ទូទាត់ បើសែកគ្មានទឹកប្រាក់គឺជនជាប់ចោទល្មើសនឹងមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ ។

៤-ជនជាប់ចោទពិតជាបានយករថយន្តម៉ាក សឺដេស S500 ផលិតឆ្នាំ ២០១០ របស់ដើមបណ្តឹងទៅបញ្ចាំនៅកាស៊ីណូ ចម្លើយនេះមានលក្ខណៈស៊ីសង្វាក់ជាមួយដើមបណ្តឹង និងសាក្សីដោយដើមបណ្តឹងយកលុយទៅលស់អស់ប្រាក់ជាង ៤០០០០$ (បួនម៉ឺនដុល្លារអាមេរិក) តែសាក្សីឈ្មោះ [redacted] ជាអ្នកយកលុយទៅលស់បញ្ជាក់ថា ខ្លួនយកប្រាក់ពីដើមបណ្តឹងសរុបចំនួន ១៧០០០$ (មួយម៉ឺនប្រាំពីរពាន់ដុល្លារអាមេរិក) ទើបទទួលបានឡានមកវិញ ចំណុចនេះតុលាការពិនិត្យពិចារណា ។ ការដែលជនជាប់ចោទអះអាងថា រថយន្តនេះជាឡានចូលហ៊ុនគ្នា គឺពុំមានភស្តុតាងណាឲ្យតុលាការជឿបានឡើយ ។

៥-ដើមបណ្តឹងទាមទារប្រាក់ដើមចំនួន ១២៧ ៥៦២$ (ដប់ពីរម៉ឺនប្រាំពីរពាន់ប្រាំរយហុកសិបពីរដុល្លារអាមេរិក) និងជម្ងឺចិត្តចំនួន ៣០០០០$ (បីម៉ឺនដុល្លារអាមេរិក) ពីជនជាប់ចោទ ។ ការទាមទារប្រាក់នេះ តុលាការពុំទទួលស្គាល់ទាំងអស់ទេ ព្រោះទឹកប្រាក់មួយចំនួនកើតចេញពីវិវាទគិច្ចសន្យា ដូច្នេះការទាមទាររបស់ដើមបណ្តឹងតុលាការទទួលស្គាល់លើការចេញសែកពីរសន្លឹក



៤៣៥

Scanned by CamScanner

ចំនួន ៤៤០០$ (បួនម៉ឺនបួនពាន់ដុល្លារអាមេរិក) និងថ្លៃយកប្រាក់ទៅលូសយករថយន្តដែលបានដាក់បញ្ចាំ រីឯប្រាក់សល់ពីនោះ ទុកសិទ្ធិឲ្យដើមបណ្តឹងប្តឹងទៅតុលាការរដ្ឋប្បវេណីទាមទារសំណងតាមច្បាប់ ។ ចំពោះប្រាកជម្ងឺចិត្តតុលាការពិចារណាតាមភាពសមរម្យ ។

៦-ការប្រព្រឹត្តរបស់ជនជាប់ចោទជាអំពើមិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ២៣១ នៃច្បាប់ស្តីពី ឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ៣៩១,៣៩២ នៃក្រមព្រហ្មទណ្ឌ ។

៧-សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការដែលសុំតំកល់បទចោទប្រកាន់ទុកដដែលមាន លក្ខណៈត្រឹមត្រូវតាមច្បាប់ ។

៨-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារឲ្យជនជាប់ចោទ ស្នើសុំឲ្យតុលាការលើកលែងចោទប្រកាន់លើកូនក្តីខ្លួននោះ គឺពុំត្រឹមត្រូវទេ ហើយចំណុចស្នើសុំឲ្យតុលាការចាត់របៀបកោះហៅសាក្សីឈ្មោះ [redacted]មកបំភ្លឺនោះគឺជាការត្រឹមត្រូវហើយ តែបើកោះហៅគឺធ្វើឲ្យអូសបន្លាយកាន់តែយូរព្រោះរឿងក្តីនេះមានសាក្សី រីឯដើមបណ្តឹងរដ្ឋប្បវេណីបំភ្លឺបានច្បាស់លាស់អាចឲ្យតុលាការសំរេចសេចក្តីបាន ។

៩-ជនជាប់ចោទឈ្មោះ [redacted] ជានីតិជនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលខុសត្រូវព្រហ្មទណ្ឌនូវអំពើរបស់ខ្លួន ។

១០-មានភស្តុតាងដាក់បន្ទុកនិងពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ភេទប្រុស អាយុ ៣៧ឆ្នាំ ពីបទ មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីខែ មិថុនា ឆ្នាំ ២០០៩ និងក្នុងឆ្នាំ ២០១១ ដែលត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

១១-ជនជាប់ចោទធ្លាប់ជាប់ពន្ធនាគារពីបទចេញសែកគ្មានទឹកប្រាក់ ហើយឥឡូវនេះបានប្រព្រឹត្តបទល្មើសចំនួនពីរដង ដូច្នេះទណ្ឌកម្មដែលត្រូវទទួលតុលាការនឹងពិនិត្យពិចារណា ។

១២-លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិរបស់ដើមបណ្តឹងឈ្មោះ អ៊ុំ វ៉ាវុឌ្ឍ បានទាមទារសំណងចំនួន ១២៧.៥៦២,៥០$ (មួយសែនពីរម៉ឺនប្រាំពីរពាន់ប្រាំរយហុកសិបពីរដុល្លារអាមេរិក និងហាសិបសេន) ជាប្រាក់ដែលជនជាប់ចោទជំពាក់កន្លងមក តុលាការពុំអាចលើកយកមកពិនិត្យសម្រេចអំពីការទាមទារសំណងនេះបានទេ ព្រោះថាជារឿងកិច្ចសន្យាក្នុងសំណុំរឿងរដ្ឋប្បវេណី។

១៣ វត្ថុតាប់យករួមមានៈ



Scanned by CamScanner

១/-ទូរស័ព្ទដៃចំនួន ០២គ្រឿង ម៉ាក Samsung និងម៉ាក Nokia ។

២/-សៀវភៅគ្រួសារលេខ ១៧៧ ចំនួន ០១ក្បាល ។

៣/-លិខិតឆ្លងដែនលេខ ០៥៣៧០១៣ ចំនួន ០១ក្បាល ។

៤/-សៀវភៅធនាគារ Cambodia Pubic Bank លេខ ០៩១២៨១ ចំនួន ០១ក្បាល ។

៥/-សែកធនាគារកម្ពុជាសាធារណៈ ចំនួន ០៣ក្បាល ។

៦/-លិខិតទិញលក់រថយន្ត ០៣សន្លឹក ។

៧/-រថយន្តមួយគ្រឿងម៉ាក RAV 4 ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ ២A ៥៥៥៥ ។

៨/-សែកធនាគារកាណាឌីយ៉ាចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ដែលមានទឹកប្រាក់ចំនួន ២៣០ 000 USD (ម្ភៃបីម៉ឺនដុល្លាអាមេរិក) ចំនួន ០១សន្លឹក ។

៩/-សែកធនាគារ May Bank ចំនួន ០៤សន្លឹក មួយសន្លឹកមានទឹកប្រាក់ចំនួន ១៧០ 000 (ដប់ប្រាំពីរម៉ឺនដុល្លាអាមេរិក) ។

១០/-សែកធនាគារកម្ពុជាសាធារណៈ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលមានទឹកប្រាក់ចំនួន ៨០ 000 USD (ប្រាំបីម៉ឺនដុល្លាអាមេរិក) ចំនួន ០១សន្លឹក ជាសម្ភារៈផ្ទាល់ខ្លួន មិនមានពាក់ព័ន្ធក្នុងរឿងក្តីឡើយ ដូច្នេះគប្បីប្រគល់ទៅអោយម្ចាស់ដើមវិញ ។

## ហេតុដូច្នេះសម្រេច

១. ផ្តន្ទាទោសឈ្មោះ [redacted] ភេទប្រុស អាយុ ៤៤ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ (បីឆ្នាំ) ពីបទៈ **មិនបំពេញកាតព្វកិច្ចចំពោះឧបករណ៍អាចជួញដូរបាន និងរំលោភលើទំនុកចិត្ត** ប្រព្រឹត្តនៅចំណុចរាជធានីភ្នំពេញ កាលពីខែ មិថុនា ឆ្នាំ ២០០៩ និងក្នុងឆ្នាំ ២០១១ តាមមាត្រា ២៣១ នៃច្បាប់ស្តីពីឧបករណ៍អាចជួញដូរបាន និងប្រតិបត្តិការទូទាត់សងប្រាក់ និងមាត្រា ៣៩១, ៣៩២ នៃក្រមព្រហ្មទណ្ឌ ។

២. បង្គាប់ឲ្យឈ្មោះ [redacted] ផ្តល់សំណងថ្លៃចេញសែក ថ្លៃយកប្រាក់ទៅលស់យករថយន្ត និងប្រាក់ជម្ងឺចិត្តសរុបចំនួន ៤០០០០$ (បួនម៉ឺនដុល្លាអាមេរិក) ឲ្យទៅដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការទាមទារលើសពីនេះត្រូវច្រានចោល ។

៣. វត្ថុចាប់យករួមមានៈ

១/-ទូរស័ព្ទដៃចំនួន ០២គ្រឿង ម៉ាក Samsung និងម៉ាក Nokia ។

២/-សៀវភៅគ្រួសារលេខ ១៧៧ ចំនួន ០១ក្បាល ។

៣/-លិខិតឆ្លងដែនលេខ ០៥៣៧០១៣ ចំនួន ០១ក្បាល ។

៤/-សៀវភៅធនាគារ Cambodia Pubic Bank លេខ ០៩១២៨១ ចំនួន ០១ក្បាល ។



Scanned by CamScanner

៥/-សែកធនាគារកម្ពុជាសាធារណៈ ចំនួន ០៣ក្បាល ។

៦/-លិខិតទិញលក់រថយន្ត ០៣សន្លឹក ។

៧/-រថយន្តមួយគ្រឿងម៉ាកRAV4 ពណ៌ទឹកមាស ពាក់ស្លាកលេខ ភ្នំពេញ២A ៨៥៥៨

៨/-សែកធនាគារកាណាឌីយ៉ាចុះថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១២ ដែលមានទឹកប្រាក់ចំនួន ២៣០ ០០០ USD (ម្ភៃបីម៉ឺនដុល្លារអាមេរិក) ចំនួន ០១សន្លឹក ។

៩/-សែកធនាគារ May Bank ចំនួន ០៤សន្លឹក មួយសន្លឹកមានទឹកប្រាក់ចំនួន ១៧០ ០០០ (ដប់ប្រាំពីរម៉ឺនដុល្លារអាមេរិក) ។

១០/-សែកធនាគារកម្ពុជាសាធារណៈ ចុះថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០០៨ ដែលមានទឹកប្រាក់ចំនួន ៨០ ០០០ USD (ប្រាំបីម៉ឺនដុល្លារអាមេរិក) ចំនួន ០១សន្លឹក ។ តាមកំណត់ហេតុទទួលវត្ថុតាងលេខ ៩៤ អយធ ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ត្រូវប្រគល់ឲ្យម្ចាស់ដើមវិញ ។

៤/-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១២ ចំពោះមុខជនជាប់ចោទ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខមេធាវីការពារជនជាប់ចោទ និងមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជី**

ហត្ថលេខា និងត្រា: [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និងត្រា: [redacted]

ផ្ទួនឃើញ

ចៅក្រមជំនុំជម្រះ

[redacted]

"បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម"

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០១២

ក្រឡាបញ្ជី

[redacted]



Scanned by CamScanner